UNITED NATIONS INDUSTRIAL DEVELOPMENT ORGANIZATION

CEOI No: 01

សេចក្តីប្រកាសរកអ្នកចាប់អារម្មណ៍ចូលរួមគម្រោង (CEOI)

គម្រោងវិនិយោគថាមពលកកើតឡើងវិញក្នុងវិស័យឧស្សាហកម្ម

ការរៀបចំបង្កើតស្ថានីយផលិតថាមពលដើរដោយជីវឧស្ម័ន និងការវិនិយោគធ្វើការកែលម្អបច្ចេកវិទ្យាជីវឧស្ម័ន

---

1. សាវតារគម្រោង

អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម (ហៅកាត់ថា យូនីដូ-UNIDO) កំពុងអនុវត្តគម្រោងមួយគាំទ្រថវិកាដោយអង្គការមូលនិធិបរិស្ថានសកល (GEF) នៅក្នុងវដ្តទី៥ GEF-5 ដែលមានឈ្មោះថា "គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយជម្រុញការវិនិយោគលើឡជីវឧស្ម័នខ្នាតធំ" ជាភាសាអង់គ្លេសហៅថា "Reduction of GHG emission through Promotion of Commercial Biogas Plants"។ គម្រោងនេះកំពុងត្រូវបានអនុវត្តដោយមានការសហការជាមួយក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ គម្រោងនៅក្នុងវដ្តទី៥របស់ GEF នេះ មានគោលដៅលើកកម្ពស់ការវិនិយោគទៅលើសហគ្រាសអគ្គិសនីជនបទផ្អែកលើជីវឧស្ម័ន នៅតាមកសិដ្ឋានចិញ្ចឹមជ្រូក ដើម្បីពង្រីកអគ្គិសនីភ្ជាប់នឹយកម្មតំបន់ជនបទនៃប្រទេសកម្ពុជា។

គោលបំណងរបស់គម្រោងនេះ គឺលើកកម្ពស់ការវិនិយោគទៅលើសហគ្រាសអគ្គិសនីជនបទផ្អែកលើជីវឧស្ម័ន ហៅជាអង់គ្លេសថា Rural Electrification Enterprise (REE) ដើម្បីពង្រីកអគ្គិសនីភ្ជាប់នឹយកម្មតំបន់ជនបទនៃប្រទេសកម្ពុជា។ សកម្មភាពនានាដែលបានស្នើឡើងតាមរយៈគម្រោងនេះ នឹងជួយបង្កលក្ខណៈឱ្យវិស័យចិញ្ចឹមសត្វពាហនៈ ការកែច្នៃកសិផល និង ការកែច្នៃស្បៀងអាហារ ឱ្យចេះប្រើប្រាស់កាកសំណល់សរីរាង្គងាយបំបែកធាតុ (ដូចជា លាមកសត្ត និង ទឹកសំណល់បញ្ចេលចោលដោយការកែច្នៃស្បៀងអាហារ ជាដើម) ដែលវិស័យនេះបង្កើតបាន សម្រាប់ផលិតថាមពលផង និងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ផង (GHG) ទៅជំនួសប្រព័ន្ធផលិតថាមពលតាមរយៈម៉ាស៊ីនភ្លើងដើរដោយប្រេងម៉ាហ៊ីរ្ទូតវិញ។ គម្រោងនេះមានគោលដៅឈានទៅដំឡើងសមត្ថភាពផលិតអគ្គិសនីសរុបឱ្យបានដល់អានុភាព 1 MW នៅក្នុងអំឡុងពេលប្រតិបត្តិការរបស់វា។

លើសពីនេះ គម្រោងត្រូវបានរំពឹងទុកថានឹងជួយលុបបំបាត់ចេញនូវឧបសគ្គនានា (ដូចជា ការយល់ដឹង សមត្ថភាពបច្ចេកទេស និងបរិស្ថានអំណោយផលសម្រាប់ការវិនិយោគលើគម្រោងជីវឧស្ម័ន) ដែលរារាំងដល់ការយកកាកសំណល់សរីរាង្គងាយបំបែកធាតុមកប្រើប្រាស់សម្រាប់ផលិតអគ្គិសនីឱ្យបានទូលំទូលាយ។ ការលុបបំបាត់បាននូវបារឧបសគ្គទាំងនេះ នឹងចូលរួមចំណែកដល់ការបង្កើនចំណូលជាតិ និងកែលម្អកម្រិតជីវភាពរស់នៅរបស់ប្រជាជនទូទៅ ទៀតផង។

2. គោលបំណងរបស់លក្ខខណ្ឌយោង

សេចក្តីប្រកាសស្វែងរកអ្នកចាប់អារម្មណ៍ (CEoI) នេះត្រូវបានផ្សព្វផ្សាយជម្រាបជូនជាព័ត៌មានដល់សាធារណជនទាំងឡាយណាដែលចាប់អារម្មណ៍ក្នុងការវិនិយោគលើថាមពលកកើតឡើងវិញ តាមរយៈបច្ចេកវិទ្យាជីវឧស្ម័ន នៅតាមឧស្សាហកម្មខ្នាតតូចនិងមធ្យមនៅក្នុងវិស័យចិញ្ចឹមសត្វ៣ហាន: ការកែច្នៃកសិផល និងការកែច្នៃស្បៀងអាហារ ក្នុងប្រទេសកម្ពុជា ដែលក្នុងនោះអ្នកដេញថ្លៃនឹងត្រូវចេញថវិកាបជិភាគសម្រាប់យកទៅអនុវត្តគម្រោងនេះ ដែរ។

នៅក្នុងគោលបំណងនេះ អង្គការយូនីដូ កំពុងស្វែងរកក្រុមហ៊ុន ឬចង្កោមក្រុមហ៊ុននានាដែលគ្រោងធ្វើការវិនិយោគលើគម្រោងណាដែលពាក់ព័ន្ធការផលិត និងការប្រើប្រាស់ជីវឧស្ម័ន។ សម្រាប់ករណីចង្កោមក្រុមហ៊ុន សមាជិករបស់ចង្កោមក្រុមហ៊ុនត្រូវរួមគ្នាផ្តល់ព័ត៌មានដែលជាតម្រូវការចាំបាច់ ហើយក៏ត្រូវកំណត់ឱ្យបានច្បាស់លាស់ផងដែរនូវអត្តសញ្ញាណរបស់សមាជិកណាមួយរបស់ខ្លួនឱ្យដឹកនាំគម្រោងនេះ។ <u>ជាការរំពឹងទុក ក្រុមហ៊ុននានា ឬចង្កោមក្រុមហ៊ុននឹងត្រូវចេញទុនសម្រាប់ធ្វើការវិនិយោគ និងរៀបចំបង្កើតស្ថានីយផលិតថាមពលដើរដោយជីវឧស្ម័ន ឬជម្រើសសម្រាប់កែលម្អការផលិតជីវឧស្ម័ន ដោយប្រើប្រាស់ថវិការបស់ខ្លួនផ្ទាល់ ជាមុនសិន។</u>

3. អំណោយថវិកាគាំទ្រគម្រោង

អំណោយថវិកាគាំទ្រនឹងត្រូវបានផ្តល់សម្រាប់បំពេញការចំណាយបន្ថែមរបស់គម្រោង បន្ទាប់ពីមានការផ្ទៀងផ្ទាត់លទ្ធផលដែលការអនុវត្តសម្រេចបានជាដំណាក់ៗ ស្របតាមគោលកំណត់ដែលព្រមព្រៀងគ្នារួច។

អង្គការ យូនីដូ នឹងផ្តល់ទុនគាំទ្រសម្រាប់ការដំឡើងប្រព័ន្ធឡជីវឧស្ម័ននៅក្នុងតម្លៃមិនលើពី 500 USD/kW ឬច្រើនបំផុតត្រឹម 100,000 USD ក្នុងមួយគម្រោង (ប្រព័ន្ធឡជីវឧស្ម័ន) នៅក្រោយពេលបានធ្វើការផ្ទៀងផ្ទាត់ត្រឹមត្រូវទៅលើសមត្ថភាពដែលបានដំឡើងរួច។ ការដំឡើងប្រព័ន្ធឡជីវឧស្ម័ននឹងទទួលបានការគាំទ្រសម្រាប់តែសំណើគម្រោងទាំងឡាយណាដែលមានការសិក្សាសមិទ្ធលទ្ធភាពជាវិជ្ជមាន និងដែលបំពេញបានសព្វគ្រប់តាមលក្ខណៈវិនិច្ឆ័យភាពពេញសិទ្ធិ នៅពេលចុះហត្ថលេខាលើកិច្ចសន្យាជាមួយអង្គការយូនីដូ។ ថវិកាអំណោយរបស់មូលនិធិបរិស្ថានសាកល នឹងមិនត្រូវបានយកទៅប្រើប្រាស់ធ្វើសកម្មភាពណាផ្សេងទាំងអស់ដែលមិនស្ថិតក្រោមវិសាលភាពនៃការងារនេះដូចមានចែងក្នុងតារាងខាងក្រោម។ ក្រុមហ៊ុននានាត្រូវសន្យាផ្តល់ថវិកាវិនិយោគ និងការគាំទ្រចាំបាច់នានាដើម្បីអនុវត្តគម្រោងឱ្យបានសម្រេច (ត្រូវផ្តល់ភ័ស្តុតាងគ្រប់គ្រាន់ស្តីពីការធ្វើហិរញ្ញប្បទាននៅដំណាក់កាលជាបន្តបន្ទាប់ទៀត)។

អំណោយថវិកាគាំទ្រនឹងមានក្នុងតម្លៃរហូតដល់ទៅ 500 USD/kW ហើយវានឹងអាស្រ័យទៅតាមវិសាលភាពរបស់គម្រោង ឧទាហរណ៍ មានគម្រោងប្រព័ន្ធផលិតថាមពលមានឡជីវឧស្ម័នជាមួយផង ឬគ្មានម៉ាស៊ីនភ្លើង ឬគ្រាន់តែជាគម្រោងកែលម្អប្រព័ន្ធឡជីវឧស្ម័ន (ដូចជា ប្រព័ន្ធប្រព្រឹត្តិកម្មឧស្ម័ន, នាឡិកាស្ទង់កម្រិតឧស្ម័ន, រណ្តៅលាមកមានក្រាលតង់ពីក្រោម (improved covered lagoon) បំពង់ចំហេះឧស្ម័ន ជាដើម)។

គម្រោងមានវិសាលភាពផ្សេងគ្នានឹងមានសិទ្ធិទទួលបានការគាំទ្រថវិកានៅកម្រិតខុសគ្នា នៅក្រោមសេចក្តីប្រកាសនេះ។ សូមមើល <u>គំរូវិសាលភាពនៃគម្រោង</u>ផ្សេងៗគ្នានៅក្នុងតារាងខាងក្រោម៖

	វិសាលភាព១៖ ប្រព័ន្ធផលិតថាមពលជីវឧស្ម័នរួមមានឡជីវឧស្ម័នដែរ **Scope 1: Biogas Energy Generation System including digester**	វិសាលភាព២៖ ប្រព័ន្ធផលិតថាមពលជីវឧស្ម័ន **Scope 2: Biogas Energy Generation System**	វិសាលភាព៣៖ ការកែលម្អប្រព័ន្ធជីវឧស្ម័នដែលមានស្រាប់ **Scope 3: Biogas System Improvement**
a. Biogas generator set (ម៉ាស៊ីនភ្លើងជីវឧស្ម័ន១ឈុត)	X	X	
b. Gas treatment: Biogas dehumidification and desulphurisation unit ប្រព័ន្ធសម្អាតឧស្ម័ន៖ ការបំបាត់សំណើមនិងដកយកសារធាតុស្ពាន់ធ័រចេញពីជីវឧស្ម័ន	X	X	X
c. Gas meter (mandatory to ensure no venting of biogas) នាឡិកាស្វង់កម្រិតឧស្ម័ន (ចាំបាច់ត្រូវតែមានដើម្បីធានាកុំឱ្យមានការធ្លាយជីវឧស្ម័នចេញក្រៅ)	X	X	X
d. Biogas flare ឧបករណ៍ដុតឧស្ម័នចោល	X	X	X
e. All tubing and cabling required for installation and interconnection of components បណ្តាញបំពង់និងខ្សែចាំបាច់ត្រូវមានក្នុងការដំឡើង និងនៅក្នុងការតភ្ជាប់សមាសភាគនានារបស់ប្រព័ន្ធទាំងមូល	X	X	X
f. Transportation, installation, commissioning and training ការដឹកជញ្ជូន, ការដំឡើង, ការដាក់ឱ្យដំណើរការប្រើ, និងការហ្វឹកហ្វឺនបណ្តុះបណ្តាល	X	X	X
g. Digester system(s) (e.g. improved covered lagoon, UASB[1], CSTR)[2]; ប្រព័ន្ធឡជីវឧស្ម័ន (ឧ. រណ្តៅលាមកមានគម្របល្អប្រភេទ UASB ឬ CSTR)	X		

សហហិរញ្ញប្បទាន៖ តាមលក្ខខណ្ឌតម្រូវរបស់មូលនិធិបរិស្ថានសាកល បេក្ខជនដាក់ពាក្យត្រូវបង្ហាញថាខ្លួនមានសមត្ថភាពធ្វើបដិភាគហិរញ្ញវត្ថុដល់គម្រោង។ នៅក្នុងសំណើវិនិយោគរបស់ខ្លួន បេក្ខជនដាក់ពាក្យត្រូវបង្ហាញចំនួនទឹកប្រាក់ថវិកាបដិភាពដែលខ្លួននឹងកៀរគរបាន (ជាសាច់ប្រាក់ក្តី ជាសម្ភារតំណាងក្តី) នៅក្នុងអំឡុងពេលដំណើរការអនុវត្តគម្រោង និងបង្ហាញអំពីប្រភពរបស់ថវិកាបដិភាគផងដែរ។

4. លក្ខណៈវិនិច្ឆ័យភាពពេញសិទ្ធិ/លក្ខខណ្ឌសម្រាប់ទទួលបានអំណោយថវិការ្ទ្ធ្ធ ... គម្រោង

សេចក្តីប្រកាសស្វែងរកអ្នកចាប់អារម្មណ៍ (CEoI) នេះត្រូវបានផ្សព្វផ្សាយជម្រាបជូនជាព័ត៌មានដល់សាធារណជនទាំងឡាយណាដែលចាប់អារម្មណ៍ក្នុងការវិនិយោគលើថាមពលកកើតឡើងវិញ តាមរយៈបច្ចេកវិទ្យាជីវឧស្ម័ន នៅតាមឧស្សាហ

[1] *Upflow Anaerobic Sludge Blanket*
[2] *Continuously Stirred Tank Reactor*

កម្មន្តតូចនិងមធ្យមនៅក្នុងវិស័យចិញ្ចឹមសត្វ៣ហាន: ការកែច្នៃកសិផល និងការកែច្នៃស្បៀងអាហារ ក្នុងប្រទេសកម្ពុជា ដែលក្នុងនោះអ្នកដេញថ្លៃនឹងត្រូវជួយចេញថវិកាបដិភាគសម្រាប់យកទៅអនុវត្តគម្រោង។ ៣ក្យសម្តែងចំណាប់អារម្មណ៍ធ្វើការវិនិយោគដែលនឹងមកកាន់យូនីដូ ត្រូវបំពេញតាមលក្ខណៈវិនិច្ឆ័យភាពពេញសិទ្ធិ ដូចខាងក្រោមនេះ៖

1. **វិស័យ៖** វិស័យចិញ្ចឹមសត្វ៣ហាន: និងវិស័យកសិ-ឧស្សាហកម្មនៅកម្ពុជា (រួមមាន តែមិនកំហិតចំពោះ: កសិដ្ឋានចិញ្ចឹមជ្រូក, កសិដ្ឋានចិញ្ចឹមសត្វយកទឹកដោះ, ទីសត្តឃាត, ក្រុមហ៊ុនកែច្នៃម្សៅដំឡូងមី, រោងចក្រកៅស៊ូ, រោងចក្រចម្រាញ់ដូងប្រេង, រោងចក្រកែច្នៃអាហារឬផ្លែឈើ);
2. **វត្ថុធាតុដើម៖** កាកសំណល់សរីរាង្គដែលងាយបំបែកធាតុដីវ: មានដូចជា លាមកសត្វ ឬកាកសំណល់ពីការកែច្នៃឧស្សាហកម្ម និងទឹកសំណល់ ជាដើម។ អ្នកដេញថ្លៃត្រូវធានានិងបង្ហាញថា មានវត្ថុធាតុដើមចេញពីប្រភពផ្គត់ផ្គង់ជាប់ជារៀងរហូត។
3. **និរន្តរភាព៖**
   - គម្រោងត្រូវតែមានលទ្ធភាពផ្តល់ផលចំណេញនិងមាននិរន្តរភាពរហូត។ អ្នកដេញថ្លៃត្រូវមានភ័ស្តុតាងបញ្ជាក់ថាគម្រោងដែលខ្លួនប្រុងនឹងធ្វើការវិនិយោគទៅលើ នឹងអាចរកផលចំណេញបាននៅក្នុងប្រទេសកម្ពុជា។ ឧទាហរណ៍ ចំណូលបានមកពីស្ថានីយជីវឧស្ម័នអាចផ្គត់ផ្គង់ដល់ការចំណាយប្រតិបត្តិការរបស់គម្រោងទាំងស្រុងបាន។
   - អ្នកទទួលផលពីគម្រោងនេះត្រូវមានសមត្ថភាពផ្នែកគ្រប់គ្រងនិងបច្ចេកទេស ក្នុងការដំណើរការស្ថានីយជីវឧស្ម័ន និងស្ថិតលើមូលដ្ឋានសេដ្ឋកិច្ចល្អសម្រាប់ធ្វើហិរញ្ញប្បទានបដិភាគចាំបាច់ និង/ឬសម្រាប់ធ្វើការសងបំណុល និងដើម្បីផ្តល់ការធានាចាំបាច់សម្រាប់ការខ្វីឥណទានយកទៅប្រើប្រាស់ក្នុងគម្រោង។
   - ការរៀបចំរចនាបថរបស់ស្ថានីយជីវឧស្ម័ន, គុណភាពរបស់គ្រឿងបរិក្ខារ, ការសាងសង់ឬការដំឡើង និងការធ្វើប្រតិបត្តិការ (រួមទាំងការថែទាំផង) របស់ប្រព័ន្ធទាំងមូល ត្រូវតែធានាឱ្យបានស្ថានីយជីវឧស្ម័នមានអាយុកាលដំណើរការបានយ៉ាងតិចណាស់ក៏១០ឆ្នាំដែរ។
   - គម្រោងនេះចាំបាច់ត្រូវមានវិធានការធានាយ៉ាងណាកុំអោយមានការលេចធ្លាយជីវឧស្ម័នចេញក្រៅ។
   - អត្ថប្រយោជន៍ផ្នែកសង្គម-សេដ្ឋកិច្ច៖ គម្រោងនេះត្រូវនាំមកនូវអត្ថប្រយោជន៍ជាក់លាក់ និងជាបិរមាណដុំកំភួនដល់សង្គម សេដ្ឋកិច្ច និងបរិស្ថាន តាំងពីដើមរហូតដល់ចប់ ។
4. **គោលដៅរបស់សេចក្ដីប្រកាស៖** សេចក្ដីប្រកាសស្វែងរកអ្នកចាប់អារម្មណ៍នេះ (CEoI) ជាការប្រកាសចំហដល់អង្គភាពឯកជន និងសាធារណៈ, អង្គការមិនមែនរដ្ឋាភិបាល, និងអង្គការសហគមន៍ គ្រប់ប្រភេទ។
5. អ្នកដាក់ពាក្យសុំ (កសិដ្ឋានចិញ្ចឹមសត្វ ឬអង្គភាពកសិ-ឧស្សាហកម្ម នានា) ត្រូវមានវត្តមានប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ហើយមានអាជ្ញាប័ណ្ណប្រកបអាជីវកម្មត្រឹមត្រូវស្រេបតាមច្បាប់នៃប្រទេសកម្ពុជា។
6. **ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់៖** គម្រោងត្រូវមានសក្តានុពលក្នុងការកាត់បន្ថយបំភាយឧស្ម័នផ្ទះកញ្ចក់ដែលអាចប្រៀបធៀបបានជាមួយសេណារីយោដែលមានស្រាប់។
7. ប្រព័ន្ធដែលដំឡើងរួចត្រូវមានសមត្ថភាពផលិតថាមពលបាន 50kW យ៉ាងតិចបំផុត។
8. ប្រព័ន្ធឡជីវឧស្ម័នដែលដំឡើងនៅក្រោមគម្រោងនេះ ត្រូវមានការរៀបចំរចនាយ៉ាងណាកុំឱ្យទឹកក្រោមដីជ្រាបចូល និងកុំឱ្យឧស្ម័នធ្លាយចេញទៅក្នុងបរិយាកាស បាន។

9. គម្រោងដែលនឹងទទួលការគាំទ្រអាចមានសមាសភាគជាគម្រោងតូចៗផ្ទុំចូលគ្នា ស្ថិតនៅទីតាំងផ្សេងៗគ្នា អាស្រ័យទៅលើធនធានជីវម៉ាស់ដែលមាន។
10. ស្ថានីយផលិតថាមពលជីវឧស្ម័ន នឹងផ្តល់កំដៅនិង/ឬថាមពលដែលត្រូវបានផលិតចេញនិងប្រើប្រាស់សម្រាប់បម្រើសេចក្តីត្រូវការរបស់កសិដ្ឋាន ឬសម្រាប់បម្រើសេចក្តីត្រូវការរបស់អតិថិជនផ្សេងៗ ឧទាហរណ៍តាមរយៈ បណ្តាញផ្គត់ផ្គង់អគ្គិសនី ជាដើម។
11. ក្នុងករណីដែលអគ្គិសនីដែលផលិតបានពីគម្រោងជីវឧស្ម័ននេះ ត្រូវបានយកទៅភ្ជាប់ជាមួយបណ្តាញចែកចាយជាតិ ឬផ្តល់ទៅឱ្យអ្នកប្រើប្រាស់ឯកជនផ្សេងទៀត អ្នកដេញថ្លៃគម្រោងចាំបាច់ត្រូវចាត់ចែងឱ្យមានស្រេចបាច់នូវកិច្ចព្រមព្រៀង លិខិតអនុញ្ញាត និងលិខិតយល់ព្រមនានា រួមទាំង កិច្ចព្រមព្រៀងទិញអគ្គិសនី (Power Purchase Agreement) ផង ក្នុងអំឡុងពេល ៦ខែ បន្ទាប់ពីទទួលបានកិច្ចសន្យាពីអង្គការ យូនីដូ។
12. វិនិយោគិននឹងត្រូវបានតម្រូវឱ្យចេញថវិកាអនុវត្តគម្រោងរៀបចំប្រព័ន្ធជីវឧស្ម័ន ជាមុនសិន។
13. ក្រុមហ៊ុន ស្ថាប័ន ឬអង្គការដែលដើរតួជាដៃគូក្នុងកិច្ចសន្យា ត្រូវតែមានចុះបញ្ជីស្របច្បាប់នៅក្នុងប្រទេសកម្ពុជា។

5. ការបញ្ជាបយេនឌ័រ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចាត់ទុកស្ត្រីជាក្រុមពិសេសមួយដែលត្រូវមានការការពារ។ រដ្ឋធម្មនុញ្ញចែងថា ស្ត្រីមានសិទ្ធិស្មើគ្នាចំពះមុខច្បាប់ដូចបុរសដែរ និងគូសបញ្ជាក់ថែមទៀតថា ស្ត្រីមានសិទ្ធិទទួលបានឱកាសស្មើភាពនៅក្នុងវិស័យនយោបាយ សង្គម និង សេដ្ឋកិច្ច។ យោងតាមអង្គការ UN Women នារីកម្ពុជានៅតែជួបបញ្ហាប្រឈមច្រើនៅឡើយ រាប់ទាំងបញ្ហាសមត្ថភាពចូលរួមឱ្យមានប្រសិទ្ធភាពនៅក្នុងការធ្វើសេចក្តីសម្រេចនិងភាពជាអ្នកដឹកនាំ ទោះបីជារដ្ឋធម្មនុញ្ញបច្ចុប្បន្នបានផ្តល់មូលដ្ឋានសិទ្ធិទូលំទូលាយសម្រាប់បង្កើតក្របខណ្ឌមួយដើម្បីពង្រីកបុព្វហេតុឱ្យមានសមភាព រវាងនារីនិងបុរសក็ដោយ។

អង្គការ យូនីដូ តម្រូវឱ្យគម្រោងបញ្ចូលទិដ្ឋភាពនៃបញ្ហាយេនឌ័រឱ្យបានគ្រប់ជ្រុងជ្រោយ រាប់ចាប់តាំងពីដំណាក់កាលគិតគូរបង្កើតគម្រោង, ដំណាក់កាលរៀបចំផែនការ, ដំណាក់កាលអនុវត្ត, ដំណាក់កាលពិនិត្យតាមដាននិងចែករំលែកបទពិសោធន៍ ដើម្បីធានាថាស្ត្រីមានឱកាសស្មើភាពក្នុងការចូលរួម ធ្វើការរួមចំណែក និងទទួលបានអត្ថប្រយោជន៍ពីធនធានសកម្មភាព និង លទ្ធផលរបស់គម្រោង ដែរ។

6. នីតិវិធីដាក់ពាក្យ

ភាគីចាប់អារម្មណ៍ ដែលអាចបំពេញបានតាមលក្ខខណ្ឌតម្រូវខាងលើ សូមដាក់ពាក្យសំណើដេញថ្លៃគម្រោងរបស់ខ្លួនឱ្យត្រឹមត្រូវតាមបែបទឧបសម្ព័ន្ធ១ **Annex 1 – UNIDO TEMPLATE FOR SUBMISSION OF EXPRESSION OF INTEREST FOR BIOGAS INVESTMENT PROJECT PROPOSAL(S)** ឱ្យបានត្រឹម ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០។

ឯកសារពាក្យស្នើសុំដេញថ្លៃត្រូវដាក់ទៅឱ្យអង្គការ យូនីដូ ជាភាសាអង់គ្លេស (អមដោយឯកសារជាភាសាខ្មែរ)។ សេវានានាដែលបានស្នើឡើងនៅក្នុងពាក្យសុំដេញថ្លៃនោះនឹងត្រូវឆ្លងកាត់ការពិនិត្យ និងការវាយតម្លៃដោយផ្អែកលើសមត្ថភាពនិងអនុលោមភាពរបស់សំណើ និងផ្អែកលើការឆ្លើយតបបានត្រឹមត្រូវទៅនឹងលក្ខខណ្ឌតម្រូវដូចមានចែងនៅក្នុងលក្ខខណ្ឌយោង (ToR) និងនៅក្នុងឧបសម្ព័ន្ធនានា។ ពាក្យសុំដេញថ្លៃណាដែលមិនបានបំពេញតាមលក្ខខណ្ឌតម្រូវ នឹងត្រូវបាន

បដិសេធចោល។ លោក លោកស្រីអាចមើលគំរូកិច្ចសន្យា និងឯកសារឧបសម្ព័ន្ធ និងព័ត៌មានថែមទៀត នៅលើវ៉ិបសាយ តម្កល់បែបបទលទ្ធកម្មរបស់អង្គការ យូនីដូ បាន។

រាល់សំណួរនិងចម្លើយដែលលោក លោកស្រីមាន សូមមេត្តាផ្ញើតាមអ៊ីមែលទៅកាន់ឈ្មោះ Jossy Thomas (J.THOMAS@unido.org) ហើយចម្លងជូនឈ្មោះ Katharina Proestler (K.PROESTLER@unido.org), Serey Vathana Hou (S.HOU@unido.org), Rachana Kong (R.KONG@unido.org) ផងដែរ។

United Nations Industrial Development Organization (UNIDO)
UNIDO Country Office, Cambodia
Phnom Penh Center, Building "A", Room 611, 6th Floor
Corner Preah Sihanouk Blvd (St. 274) & Preah Sothearos Blvd
Sangkat Tonle Bassac, Khan Chamkarmon, Phnom Penh

UNIDO Project No: 120118 – Reduction of Greenhouse Gas Emission through Promotion of Commercial Biogas Plant in Cambodia
គម្រោងយូនីដូលេខ No: 120118 – "កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ (GHG) តាមរយៈការលើកកម្ពស់ការវិនិយោគធ្វើស្ថានីយផលិតជីវឧស្ម័នជាលក្ខណៈអាជីវកម្មនៅកម្ពុជា"

ក្នុងករណីដែលលោក លោកស្រីត្រូវការជំនួយ សូមមេត្តាទាក់ទងទៅកាន់មជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ (BTIC) ដើម្បីទទួលបានសេវាដូចមានរាយនាមខាងក្រោម (អាចតម្រូវឱ្យបង់ថ្លៃឈ្នួលជំនួយសេវា)៖

- សេវាវាយតម្លៃមុនធ្វើការសិក្សាសមិទ្ធលទ្ធភាពគម្រោង
- ការសិក្សាសមិទ្ធលទ្ធភាពផ្នែកបច្ចេកទេសនិងសេដ្ឋកិច្ច
- សេវាគ្រប់គ្រងលទ្ធកម្ម
- សេវារៀបចំសំណើគម្រោង
- សេវាដំឡើង ដាក់ឱ្យដំណើរការ និង ហ្វឹកហ្វឺនបណ្តុះបណ្តាល
- សេវាពិនិត្យតាមដានគ្រឿងបរិក្ខារ/ដំណើរការរបស់ប្រព័ន្ធទាំងមូល

ព័ត៌មានសម្រាប់ទាក់ទង៖

Mr. Lor Lytour
Royal University of Agriculture, Dangkor District, Phnom Penh, Cambodia, P.O. Box: 2696
Tel: (855) 23 219 829; (855)11973672; (855)17488801
Fax: (855) 23 219 753 690
Email: btic@rua.edu.kh;
Web: www.btic-rua.org

ដំណើរការចាត់ការពាក្យសុំដេញថ្លៃ និងពេលវេលាប្រហាក់ប្រហែល មានបង្ហាញជូននៅក្នុងតារាងខាងក្រោម៖

ជំហាន	កំណត់សម្គាល់	ពេលវេលា
0. ប្រកាសរកអ្នកចាប់អារម្មណ៍ (CEoI)	ចុះផ្សាយការប្រកាសអំពីអំណោយហិរញ្ញប្បទានតាមអ៊ីនធឺណិត អ៊ីមែល បណ្តាញផ្សព្វផ្សាយសង្គម និងលើទំព័រកាសែត	៦សប្តាហ៍ (ថ្ងៃទី៣១ ខែមករា ឆ្នាំ ២០២)
1.បេក្ខជនដាក់ពាក្យចាប់អារម្មណ៍សុំដេញថ្លៃ	បេក្ខជនទាំងអស់ត្រូវពិនិត្យមើលភាពពេញសិទ្ធិសុំដេញថ្លៃរបស់ខ្លួនដោយផ្ទៀងផ្ទាត់ជាមួយលក្ខណៈវិនិច្ឆ័យរបស់យូនីដូ , បំពេញពាក្យសុំដោយប្រើទម្រង់បែបបទនៅក្នុងឧបសម្ព័ន្ធ១	

	Annex 1 ដោយភ្ជាប់មកជាមួយនូវឯកសារនានាសម្រាប់ទ្រទ្រង់ពាក្យសុំ និងលិខិតចាប់អារម្មណ៍សុំដេញថ្លៃទៅកាន់អង្គការយូនីដូ	
2. ការពិនិត្យដោយអង្គការយូនីដូលើភាពពេញសិទ្ធិ និងលើទិដ្ឋភាពបច្ចេកទេសរបស់ពាក្យសុំ	គម្រោងដីវឧស្ម័ននៃអង្គការយូនីដូធ្វើការពិនិត្យ និងវាយតម្លៃពាក្យសុំដេញថ្លៃ	៤សប្តាហ៍ (កុម្ភៈ-ឧមីនា ២០២០)
3. សេចក្តីសម្រេចរបស់គម្រោងដីវឧស្ម័ន និង ការស្នើសុំឱ្យបេក្ខជនជ័យលាភីដាក់សំណើពាក្យសុំពេញលេញមួយសម្រាប់ធ្វើគម្រោង	ការជូនដំណឹងដល់បេក្ខជនដែលទទួលបានជោគជ័យក្នុងការដេញថ្លៃ និងស្នើសុំឱ្យដាក់សំណើពាក្យសុំពេញលេញមួយសម្រាប់គម្រោង (អាស្រ័យលើការចុះហត្ថលេខាលើកិច្ចព្រមព្រៀងធ្វើហិរញ្ញប្បទានសម្រាប់គម្រោងរបស់អ្នកស្នើសុំ)	
4. បេក្ខជនជ័យលាភីដាក់សំណើពាក្យពេញលេញសម្រាប់គម្រោង	បេក្ខជនពេញសិទ្ធិរៀបចំសំណើពាក្យសុំធ្វើគម្រោង (ការសិក្សាអំពីសមិទ្ធលទ្ធភាពគម្រោងជាតម្រូវការចាំបាច់ជាផ្នែកមួយនៃកញ្ចប់ពាក្យស្នើសុំ)	៦សប្តាហ៍ (មេសា ២០២០)
5. ការពិនិត្យផ្នែកបច្ចេកទេសដោយអង្គការយូនីដូ	អង្គការយូនីដូធ្វើការពិនិត្យនិងវាយតម្លៃទៅលើសំណើពាក្យសុំធ្វើគម្រោងទាំងមូល	៤សប្តាហ៍ (ឧសភា ២០២០)
6. សេចក្តីសម្រេចរបស់អង្គការយូនីដូ	ជូនដំណឹងដល់បេក្ខជនជ័យលាភី និងចេញកិច្ចសន្យាលើកទឹកចិត្ត (អាស្រ័យលើការចុះហត្ថលេខាលើកិច្ចព្រមព្រៀងធ្វើហិរញ្ញប្បទានសម្រាប់គម្រោងរបស់អ្នកស្នើសុំ)	
7. ការអនុវត្តគម្រោង	ទិញ ដំឡើង និងដាក់ឱ្យដំណើរការនូវគ្រឿងបរិក្ខារស្ថានីយដីវឧស្ម័ន។ បេក្ខជនទទួលបានកិច្ចសន្យាត្រូវផ្តល់របាយការណ៍វឌ្ឍនភាពការងាររៀបចំគម្រោងដីវឧស្ម័ន ឱ្យបានទៀតទាត់។	អតិបរមា ៩ ខែ (កុម្ភៈ ២០២១)
8. ការបង់ប្រាក់លើកទឹកចិត្ត	ប្រាក់លើកទឹកចិត្តនឹងត្រូវបានបង់តាមដំណាក់កាលនៃការអនុវត្តគម្រោង បន្ទាប់ពីមានការឯកភាពយល់ព្រមលើរបាយការណ៍វឌ្ឍនភាពការងារ។ ការបង់ប្រាក់ចុងក្រោយនឹងត្រូវបានធ្វើក្រោយពីស្ថានីយត្រូវបានដាក់ឱ្យដំណើរការដោយជោគជ័យ។	(មិថុនា ២០២០ - មេសា ២០២១)

7. ការបដិសេធ

អង្គការ យូនីដូ សូមរក្សាសិទ្ធិដាត់ចេញនូវក្រុមហ៊ុន ឬ ស្ថាប័នចាប់អារម្មណ៍ទាំងឡាយណាដែលមិនបំពេញបានតាមលក្ខខណ្ឌតម្រូវរបស់សេចក្តីប្រកាសនេះ។ មានតែក្រុមហ៊ុនជាប់ឈ្មោះក្នុងបញ្ជីខ្លីក្រោយពីការជម្រុះរួចប៉ុណ្ណោះ ដែលនឹងត្រូវបានអញ្ជើញឱ្យចូលរួមធ្វើការពិចារណាដេញថ្លៃគម្រោង។

សេចក្តីប្រកាសរកអ្នកចាប់អារម្មណ៍ (CEoI) នេះមិនមែនជាការបញ្ជាជាវសេវាទេ។ អង្គការ យូនីដូ សូមរក្សាសិទ្ធិធ្វើការផ្លាស់ប្តូរ ឬលុបចោលលក្ខខណ្ឌតម្រូវនៅពេលណាក៏បានក្នុងអំឡុងពេលចេញសេចក្តីប្រកាសនេះ និង/ឬ ក្នុងអំឡុងពេលដំណើរការបញ្ជាជាវសេវា។

គ្មានចំណុចណាមួយនៅក្នុងឬដែលទាក់ទិនជាមួយសេចក្តីប្រកាសរកអ្នកចាប់អារម្មណ៍ (CEoI) នេះត្រូវបានចាត់ទុក ដោយផ្ទាល់ក្តីឬប្រយោលក្តី ថាជាការលះបង់នូវផ្នែកណាមួយនៃបុព្វសិទ្ធិនិងឯកសិទ្ធិរបស់អង្គការយូនីដូ ឡើយ។

ថ្ងៃ ខែ ឆ្នាំ៖

_____

ថ្ងៃ ខែ ឆ្នាំ ទីកន្លែង ឈ្មោះ/ហត្ថលេខារបស់តំណាងយូនីដូ

Annex 1:

ទម្រង់បែបបទបង្ហាញចំណាប់អារម្មណ៍លើសំណើវិនិយោគគម្រោងជីវឧស្ម័ន

Expression of Interest Form
for biogas investment project proposal(s)

UNIDO RFx No: 7000003816

លោក លោកស្រីអាចបំពេញទម្រង់បែបបទនេះនៅលើកុំព្យូទ័របានដោយគ្រាន់តែចុចលើ 'Tab' ឬដោយគ្រាន់តែបណ្តើរកូនកណ្តុរលើកុំព្យូទ័រទៅចុចលើប្រអប់ចតុកោណមានពណ៌ប្រផេះ និងលើប្រអប់សម្រាប់គូសខ្វែង ឬមួយដោយសរសេរផ្ទាល់ដៃក៏បាន។ សូមចំណាំផងថា កន្លែងណាមានសញ្ញាផ្កាយ * ជាសម្គាល់ មានន័យថាត្រូវតែបំពេញព័ត៌មាន។

ផ្នែកទី1៖ ទិដ្ឋភាពទូទៅ

1.1. ឈ្មោះគម្រោង *:	*(ចំណងជើងពេញ និងអនុចំណងជើង)*	
1.2 ព័ត៌មានលម្អិតរបស់អ្នកជាក់ពាក្យ៖		
ឈ្មោះរបស់អ្នកជាក់ពាក្យ *		
ប្រភេទនៃអ្នកជាក់ពាក្យ *	**តើអង្គការរបស់អ្នកមានបេសកកម្មអ្វីទៅ (ប្រភេទធុរកិច្ច)? សូមផ្តល់ព័ត៌មានសង្ខេប ឬព័ត៌មានប្រវត្តិរបស់ក្រុមហ៊ុនឬស្ថាប័នអាណាព្យាបាល រួមទាំងរចនាសម្ព័ន្ធរបស់អង្គភាពផង;** - ក្រុមហ៊ុនឯកជន សាធារណៈ ឬ ឯកជន-សាធារណៈ - អ្នកដេញថ្លៃគម្រោងជាបុគ្គល (ត្រូវបានចុះបញ្ជីជាក្រុមហ៊ុន) - ស្ថាប័នរដ្ឋាភិបាល (ឧ. ក្រសួង, អង្គភាពផ្គត់ផ្គង់សេវាអគ្គិសនី, ភ្នាក់ងារអគ្គិសនី, សាលាក្រុង) អង្គការមិនមែនរដ្ឋាភិបាល ឬសហការណ៍	
គ្រឿងបរិក្ខារប្រើប្រាស់ជាឧបករណ៍សម្រួលដែលមានស្រាប់	សូមរៀបរាប់សង្ខេបគ្រឿងបរិក្ខារប្រើប្រាស់ជាឧបករណ៍សម្រួលដែលមានស្រាប់ ប្រសិនបើមាន	
អាសយដ្ឋាន *		
ជនសម្រាប់ទាក់ទង *		តំណែង៖
លេខទូរស័ព្ទ *		ទូរស័ព្ទចល័ត៖
អ៊ីមែល *		រ៉ូបសាយ៖
ទូរសារ		

ឈ្មោះរបស់អង្គការជាដៃគូ (ប្រសិនបើមាន)		ប្រភេទអង្គការជាដៃគូ
Address of partner organization		

1.3 បទពិសោធន៍ / ជំនាញឯកទេសរបស់ក្រុមអនុវត្តគម្រោងexpertise of project team:

សូមរំលេចបទពិសោធន៍ / ជំនាញឯកទេសពាក់ព័ន្ធជាមួយសំណើគម្រោង (ត្រូវភ្ជាប់ប្រវត្តិផ្ទាល់ខ្លួននិងប្រវត្តិការងារជាឧបសម្ព័ន្ធរបស់ពាក្យសុំ)

ក្រុមគម្រោង	ឈ្មោះអ្នកជំនាញ	តួនាទីអ្នកជំនាញសម្រាប់គម្រោង	បទពិសោធន៍និងការអប់រំពាក់ព័ន្ធគម្រោង
អ្នកជាក់ពាក្យនាំមុខ *			
អ្នកជាក់ពាក្យនាំមុខ			
ដៃគូ 1			

ផ្នែកទី3៖ ព័ត៌មានជាមូលដ្ឋានរបស់គម្រោង*

2. 1 ព័ត៌មានជាមូលដ្ឋាន			
សំណល់ងាយបំបែកធាតុជីវ:ដែលធ្លាប់ផលិតបាន	(សូមបញ្ជាក់ប្រភេទ)	តោន/មួយថ្ងៃ ម៉ែត្រគូប/មួយថ្ងៃ	
	សម្រាប់កសិដ្ឋានចិញ្ចឹមជ្រូក៖	ចំនួនជ្រូក* ជ្រូកយកសាច់ ជ្រូកពូជ	ប្រព័ន្ធបញ្ចូលបញ្ចេញអស់ៗ * (បាទ-ចាស/ទេ)
តើសំណល់ជីវម៉ាស់បច្ចុប្បន្នត្រូវបានយកទៅធ្វើអ្វីទៅ?*	(ឧទាហរណ៍ សូមបញ្ជាក់ផងប្រសិនបើសំណល់ជីវម៉ាស់ត្រូវបានលក់ចេញ ដុត ឬចាក់ចោល)		

2. 2 សង្ខេបសកម្មភាពសំខាន់ៗរបស់ក្រុមហ៊ុន៖	
សូមរៀបរាប់ដោយសង្ខេបនូវសកម្មភាពសំខាន់ៗនៃអាជីវកម្មរបស់អ្នក៖	
កសិចិញ្ចឹមសត្វពាហនៈ ឬវិស័យកសិ-ឧស្សាហកម្ម (ឧ. កសិដ្ឋានចិញ្ចឹមជ្រូក, រោងចក្រដំឡូងមី,...)*:	
បរិមាណអគ្គិសនីប្រើប្រាស់ក្នុងមួយឆ្នាំ (ថាមពលប្រមូលបាន)*	(kWh)
អត្រាតម្លៃអគ្គិសនី*	(USD/kWh) (KHR /kWh)
មានអាជ្ញាប័ណ្ណផ្គត់ផ្គង់អគ្គិសនី*	(បាទ-ចាស/ទេ) អត់មាន៖ ប្រសិនបើមាន៖ (USD/kWh) (KHR /kWh)

ឡូឧស្ម័ន*	(បាទ-ចាស/ទេ) បើបាទ-ចាស សូមភ្ជាប់រូបថតមកជាមួយ និងសូមធ្វើការពន្យល់អំពីបច្ចេកវិទ្យានិងគ្រឿងសម្ភារៈដែលបានប្រើផង ឧទាហរណ៍ បច្ចេកវិទ្យារណ្តៅលាមកមានគម្រប ជាដើម។
ការប្រើប្រាស់ទឹកប្រចាំថ្ងៃ*	(លីត្រ)
តើមានតម្រូវការថាមពលផ្សេងទៀតទេ ដូចជា ថាមពលកំដៅ ឬថាមពលត្រជាក់?*	(បាទ-ចាស/ទេ) បើមាន សូមរៀបរាប់
តើមានអ្នកប្រើប្រាស់ថាមពលណាផ្សេងទៀតនៅជុំវិញកសិដ្ឋាន ឬ រោងចក្រទេ?*	(បាទ-ចាស/ទេ) បើមាន សូមរៀបរាប់ចំនួនផ្ទះ ប្រភេទ និងទំហំរោងចក្រ សាលារៀន មន្ទីរពេទ្យ ។ល។

2.3 អត្ថាធិប្បាយបន្ថែម

ផ្នែកទី3៖ ព័ត៌មានគម្រោង (បំពេញតែក្នុងករណីណាដែលមានការសិក្សាជាមុនអំពីសមិទ្ធលទ្ធភាពគម្រោង)

3.1 ការផ្តោតផ្នែកបច្ចេកទេសរបស់គម្រោង (សូមភ្ជាប់មកជាមួយនូវការរៀបរាប់លម្អិតនៃការសិក្សាជាមុនលើសមិទ្ធលទ្ធភាពគម្រោង ប្រសិនបើមាន)			
សូមរៀបរាប់សង្ខេប និងពន្យល់អំពីលក្ខណៈសណ្ឋាន និងគោលគំនិតធំៗ (គំនិតគម្រោង/គំនិតធុរកិច្ច) ហេតុផលសម្រាប់គម្រោង និងឥទ្ធិពលទៅលើសេដ្ឋកិច្ចសង្គម និងទៅលើបរិស្ថាន*:			
ការសិក្សាជាមុនលើសមិទ្ធលទ្ធភាពគម្រោង ការវាយតម្លៃដែលមាន (សូមភ្ជាប់មកជាមួយ)៖		(បាទ-ចាស/ទេ) បើមាន សូមភ្ជាប់មកជាមួយ ប៉ុន្តែបើគ្មានទេ សូមរៀបរាប់បញ្ជាក់ថាហេតុអ្វីមិនទាន់បានធ្វើ	
សមត្ថភាពដែលរំពឹងថានឹងត្រូវបានដំឡើង៖	**បរិមាណថាមពលដែលរំពឹងថានឹងផលិតបានក្នុងមួយឆ្នាំ៖**	**សេវា(ថាមពល)ដែលរំពឹងថានឹងផ្តល់បាន៖**	
គីឡូវ៉ាត់ (អគ្គិសនី) គីឡូវ៉ាត់ (កម្តៅ)	គីឡូវ៉ាត់ម៉ោង/ឆ្នាំ (អគ្គិសនី) គីឡូវ៉ាត់ម៉ោង/ឆ្នាំ (កម្តៅ)	គីឡូវ៉ាត់ម៉ោង/ឆ្នាំ (អគ្គិសនី) – សម្រាប់ទុកប្រើក្នុងរោងចក្រខ្លួន គីឡូវ៉ាត់ម៉ោង/ឆ្នាំ (អគ្គិសនី) – បញ្ជូនចូលខ្សែបណ្តាញអគ្គិសនី	
បរិមានឧស្ម័នផ្ទះកញ្ចក់សរុបត្រូវបានកាត់បន្ថយ	សមមូលគិតជាតោន/ឆ្នាំ (t CO_{2eq}/a)		
3.2 ព័ត៌មានហិរញ្ញវត្ថុ			
ថ្លៃចំណាយប៉ាន់ស្មានសរុបរបស់គម្រោង (CAPEX) US$[3]	**ថ្លៃចំណាយលើគ្រឿងបរិក្ខារ US$ (e.g. from quotation)**	**ទុន/មូលនិធិរបស់អ្នកជាក់ពាក្យ (US$)**	**ភាគចំណែកហិរញ្ញប្បទានពីដៃគូផ្សេងទៀត (ប្រសិនបើមាន)**

[3] ចំណាយមូលធនសម្រាប់ការសាងសង់ រួមទាំងលើការងារវិស្វកម្មស៊ីវិលផង

US$	US$	US$	US$
រយៈពេលដែលអាចរំពឹងទុកថានឹងសងវិញ៖		ឆ្នាំ	

ផ្នែកទី4៖ ឯកសារអមជាមួយ

- ច្បាប់ចម្លងរបស់ច្បាប់ដើមនៃឯកសារចុះបញ្ជីរបស់ក្រុមហ៊ុន ស្ថាប័ន ឬអង្គការ ចំនួន១ច្បាប់។
- ប្រសិនបើមាន៖ របាយការណ៍ស្តីពីការសិក្សាជាមុនលើសមិទ្ធលទ្ធភាពគម្រោងធ្វើស្ថានីយដីវ៉ុនស្ម៉ន (សំណើបច្ចេកទេសនិងអាជីវកម្ម) និងព័ត៌មានស្តីពីរបៀបជ្រើសរើសអ្នកផ្គត់ផ្គង់គ្រឿងបរិក្ខារប្រព័ន្ធដីវ៉ុនស្ម៉ន។

ផ្នែកទី5៖ ការបញ្ជាក់ដោយអ្នកជាក់ពាក្យនាំមុខ

ហត្ថលេខា៖	
ឈ្មោះ៖	
តំណែងក្នុងអង្គការ៖	
ថ្ងៃ ខែ ឆ្នាំ និងទីកន្លែង៖	

ត្រាអង្គការរបស់អ្នកជាក់ពាក្យនាំមុខ៖